AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



អ្នកព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ

# ច្បាប់ក្រមង៉ុយ

- ច្បាប់ល្បើកថ្មី
- ច្បាប់កេរកោលថ្មី
- សេចក្ដីរំលឹកដាស់តឿន
- ពាក្យកាព្យប្រដៅជនប្រុសស្រី



ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស. ២៥១៦

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com

# ច្បាប់ក្រមង៉ុយ

- ច្បាប់ល្បើកថ្មី
- ច្បាប់កេរកាលថ្មី
- សេចក្ដីរំលឹកដាស់តឿន
- ពាក្យកាព្យប្រដៅជនប្រុសស្រី

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



## អារម្ភកថា

ច្បាប់ក្រមង៉ុយនេះកាលបោះពុម្ពលើកមុនៗ ចែកចេញជាបីសៀវភៅ គឺសៀវភៅទី១ មានច្បាប់ល្បើកថ្មី និងកេរកាលថ្មី. ទី២ សេចក្ដីដាស់តឿន និងទី៣ពាក្យកាព្យប្រដៅជនប្រុសស្រី ។ នៅគ្រាបោះពុម្ពលើកទី៦នេះ ដោយនិយមតាមសេចក្ដីស្នើពីមជ្ឈដ្ឋានអ្នកសិក្សាជាច្រើននាក់ដែលសុំអោយយើងផ្គុំគ្នាយកច្បាប់នេះមករួមគ្នាជាសៀវភៅមួយ ត្បិតទុកអោយនៅដោយឡែកៗជាកូនសៀវភៅតូចៗនោះនាំអោយរប៉ាត់រប៉ាយ ពិបាកថែរទាំ ។ យោបល់នេះត្រឹមត្រូវណាស់ ទើបយើងសម្រេចប្រមូលផ្ដុំបានជាសៀវភៅមួយនេះឡើង ។

ចំពោះពាក្យពេចន៍ កាព្យឃ្លោងទាំងអស់នៅក្នុងច្បាប់ទាំងប៉ុន្មាននេះ យើងគ្មានប៉ះពាល់កែប្រែសោះឡើយ សម្រួលតែរបៀបតម្រៀបឃ្លាល្បះអោយមានលំនាំទៅតាមបែបកាព្យត្រឹមត្រូវប៉ុណ្ណោះ ។

គោលបំណងធំរបស់យើងខ្ញុំមួយទៀត គឺការចង់រក្សាស្នាដៃដ៏មានតម្លៃនៃលោកតាកវី **ភិរម្យង៉ុយ ឬក្រមង៉ុយ** ព្រោះពាក្យសំដីរបស់លោកក្នុងនេះទាំងអស់សុទ្ធតែមានន័យទូលំទូលាយ ហើយប្រកបដោយខ្លឹមសារល្អណាស់មិនចេះហួសសម័យកាលនោះផង តាំងពីគ្រាលោកសរសេររហូតសព្វថ្ងៃនៅតែមានន័យត្រូវគួរនិងធ្វើគតិទូន្មានខ្លួនបាន ។

ឆ្លៀតឱកាសនេះ ពុទ្ធសាសនបណ្ឌិតសុំសម្ដែងគារវកិច្ចដ៏ជ្រាលជ្រៅចំពោះវិញ្ញាណក្ខន្ធនៃលោកកវីដ៏ឆ្នើមនេះផង ។

ភ្នំពេញ ខែ សីហា ឆ្នាំ ១៩៧២

**ពុទ្ធសាសនបណ្ឌិត្យ**

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



# ច្បាប់កេរកេរាលថ្មី

## LES BON CONSEILS

នេះបទព្រហ្មប្រាជ្ញប្រាយ ខ្ញុំអធិប្បាយលើកល្បត់ល្បង
ប្រដៅកូនចៅផង ចងជាច្បាប់ខុសនិងត្រូវ ។
កត្តិកខ្មែតគ្នេរគ្នាន់ ក្នុងវស្សន្តរដូវ
ទឹកស្រែជន់លិចស្រូវ នៅសំណល់សំណាបខ្ចី ។
គិរកាលពីព្រេងព្រឹទ្ធ ដើមគំនិតពីសេដ្ឋី
ខ្ញុំលើកគិរកាលថ្មី ថែងសេចក្តីជាបរមត្ថ ។
ក្នុងថ្ងៃពេញបូរមី ម៉ោង៨ព្រលប់ស្ងាត់
ឆ្នាំចរចត្វាក្សត្រ ផាត់សករាជកន្លងឆ្ងាយ ។
សាសនាព្រះសាមណះ បានពីរពាន់បួនរយប្លាយ
ហុកសិបកំចាយ ចាត់អធិប្បាយពីខុសត្រូវ ។
គិរកាលដំណាលទុក ជាទំនុកដំណែលនៅ
ដំណតរៀងទៅ តម្រូវចិត្តជនប្រុសស្រី ។
កូនអើយពាក្យអាពុក ជាទំនុកទំនើបថ្មី
អនិស្រោយរាយបាលី អាពុកស្តីអោយកូនស្តាប់ ។
គួរស្តាយកើ្តមែ៉ឪ កិរិយាត្រូវអោយខំត្រាប់
កិរិយាណាខុសច្បាប់ គួរក្រឡាប់ក្រឡាស់ចោល ។
ម្តាយអាពុកនឹងកូន បីដូចខ្លួននិងស្រមោល
ឃើញខុសកុំដេញដោល កុំថ្កោលទោសអ្នកមានគុណ ។
ល្ងង់ខ្លៅត្រូវតែសួរ ពាក្យអោយគួរកុំអោយស៊ុន
យកពាក្យផ្អែមជាមុន ទន់លំទោនឱនប្រតិបត្តិ ។
ទោះម៉ែឪស្លូតកាច គួរតែខ្លាចដូចមហាក្សត្រ
ម្តាយជេរពីរបីម៉ាត់ គួរតែស្ងាត់ស្ងៀមអោយឈឹង ។
ប្រដៅត្រូវតែស្តាប់ យកតម្រាប់កុំទទឹង
ម្នោម្នះចចេសរឹង នឹងហើយហៅកូនសេសកម្ម ។
ធមិអាថិចេះតែភ្លេច ជេរប្រទេចចេះតែចាំ

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



អាពុកពត់ទៅស្ដាំ អកុសលកម្មទាញទៅឆ្វេង ។
អវជាតបុត្រ ខូចបំផុតតាំងពីក្មេង
ប្រព្រឹត្តព្រើលផ្សេងៗ បើលេងអ្វីស្ដីមិនស្ដាប់ ។
មិនស្ដាយជាតិកំណើត ល្ងង់ស្លុតស្លើតដល់ចាស់ស្លាប់ ។
ត្រឹមត្រូវមិនសូវស្ដាប់ ព្រួយគេប្រាប់ទាំងយប់ថ្ងៃ ។
ម៉ែឪមានគុណណាស់ មិនសំពះខ្មាសអៀនដៃ
បើអ្នកក្រៅដទៃ វិស័យសោះសំពះបាន ។
ឆ្លើយបាទចាះចាំខ្ញុំ រាបរម្យទមនឹងសន្ដាន
ម៉ែឪឯងក្នុងឋាន ហ៊ានឆ្លើយអីអញអីអើ ។
អនុជាតបុត្រ ស្លូតបំផុតស្រណុកប្រើ
ប្រកបការប្រសើរ ដើរតាមលំអានឪ ។
ប្រដៅទទួលយក ចេះលៃលកស្ដាប់ខុសត្រូវ
ស្រណុកញាក់ធ្លាក់ផ្លូវ មិនសូវភ្លេចដំបូន្មាន ។
អតិជាតបុត្រ ល្អបរិសុទ្ធស្គាល់សីលទាន
នាំឪទៅនិព្វាន ឈានទៅរកកន្លែងសុខ ។
ចេះលើសគេដរាប ជឿបុណ្យបាបប្រែតនរក
មិនល្មោភនឹងមូត្រលាមក ភ័យនឹងភក់ភពសង្សារ ។
នេះគឺដើមបាលី បុត្រទាំងបីបែបកិរិយា
ស្រឡាញ់ណាស្អប់ណា តាមសញ្ញាចូលចិត្តចុះ ។
អវធ្លាក់ផ្លូវក្រោម ប្រព្រឹត្តព្រមតែខាងខុស
អតិជាតិមារយាទខ្ពស់ អនុនោះយ៉ាងកណ្ដាល ។
អតិ១០០មានមួយ គួរតែស្ទួយដាក់លើក្បាល
អវគឺស្រើបស្រាល ត្រអាលយកតែពីរយ៉ាង ។
អតិជាតិកំណើត គំនិតកើតពីកសាង
កុសលតម្កល់ខាង សំណាងកើតពីគំនិត ។
អនុអានាងអើយ ខ្លួនធំហើយអោយចេះគិត
ចេះកាញ់ស្គាល់ឆ្ងាយជិត ប្រព្រឹត្តយកតែខាងត្រូវ ។
រៀនរិះរកទ្រព្យធន យកប្រពន្ធមើលធុនឪ
ធុនថោកជ្រកខុសត្រូវ អ្នកកុំទៅខ្លាចបន្ទា ។

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ផ្លូវវៀចកុំបោះបង់
ឈានឈរពិចារណា
កុំដើរភ្លើភ្លេចខ្លួន
ជ្រកម្លប់សំណាក់នៅ
ឆេះខ្លោចសំបកក្រោម
មានភ្នែកអោយចេះមើល
រៀនដើរអោយមើលផ្លូវ
ម្លប់ធ្លកធ្លាប់ជ្រកដេក
ដំណែលដែលគេដាក់
ចំណាំចាំគ្រាន់បើ
ឈើណាទោសសត្រូវ
ជិតពប់យប់អាធ្រាត្រ
បន្លាគល់ដង្កត់
ដើរយប់ជិតពប់ពារ
គ្នាមុតកុំចាំផ្ទាន់
បណ្ដើមើលខ្លាំងខ្សោយ
ពាក្យពិតត្រង់ប្រាកដ
ប្រកបជាប្រស្នា
ផ្លូវពិតទាំងជិតទាំងឆ្ងាយ
អ្នកណាប្រាជ្ញាដល់
កូនអើយការកើ្តឈ្មោះ
គិតអ្វីគិតអោយវែង
កំណើតរាល់រូបកាយ
ចិញ្ចឹមជន្មជីវិត
ធ្វើស្រែចង់បានស្រូវ
ស្រែទាបមើលទំនួល
កូនអើយកើ្តមេបា
ធុញថប់ថយថោកខ្លួន
ស្រូវក្រោយអង្ករថ្លៃ

ផ្លូវព្រៃត្រង់កុំយាត្រា
ឆ្ការអោយស្អាតសឹងដើរតាម ។
ខ្លាចក្រែងជួនធ្លាក់ជ្រោះជ្រៅ
កុំបោះពៅផ្ទប់គល់ឈើ ។
ស្រពោនញោមស្លោកស្លឹកឈើ
កុំល្ងីល្ងើលង់លិតពេក ។
ធ្វើស្រែស្រូវអោយមើលមេឃ
ជាដំណេកអ្នកដំណើរ ។
ជាដំណាក់ទំនួលធ្វើ
ដើរក្រោយៗគ្រាន់ជ្រកទៀត ។
ដុះជិតផ្លូវនាំចង្អៀត
ឆ្វៀតកាប់ចេញកុំទុកវា ។
កន្លែងផុតតែភ្នែកជា
ក្រែងគ្រោះគ្នាអ្នកដើរក្រោយ ។
ឃើញគួរជាន់កុំបណ្ដោយ
អោយពិនិត្យពិចារណា ។
ត្រូវច្រើនបទច្រើនប្រការ
ប្រាជ្ញាអាប់ស្លាប់នឹងឆ្ងល់ ។
សព្វសុសសាយមិនសេសសល់
ដឹងយោបល់ច្រើនកន្លែង ។
កុំចង់រស់តែម្នាក់ឯង
ក្រែងក្រក្រោយស័យគំនិត ។
ចេញជួញឆ្ងាយស្ដាយជួញជិត
គិតអោយស្រេចទើបបានស្រួល ។
ដើមរដូវធ្វើស្រែទួល
លើកទំនប់អោយមាំមួន ។
ចាំរក្សាមើលថែថួន
ជួនជាក្សត់គេថាខ្សោយ ។
លក់សំចៃទុកឆ្នាំក្រោយ

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



អ្នកក្រកញ្ឆយ១ អោយអ្នកសុំជាងអ្នកខ្ចី ។
សប្បុរសពេកថយធន មូទូជនថយរាសី
ប្រពន្ធល្អច្រើនអាប់ប្តី ពាក្យអប្រិយចាញ់អាត្មា ។
ឈើផ្លែចាញ់សន្លឹក ត្រីវីកទឹកមិនថ្លា
កំណាញ់ក្រៅតម្រា សោតសឹងអាប់ប្រយោជន៍យស ។
នឹងអោយ១មើលភាព អោយអ្នកទាបជាងអ្នកខ្ពស់
អ្នកទិញឈប់សិនចុះ ក្នុងតែរស់មិនស្លាប់ងាយ ។
កំណាញ់ហួសកំណត់ ពាក្យអ្នកខ្សត់ខ្សបនិយាយ
ទេវតាផ្គន្ទាទាយ រលាយអស់រលស់ឯង ។
សទ្ធាមើលធនធាន ជាតិអ្នកមានមិនអង្វែង
កំណាញ់ដោយកន្លែង ក្រែងគ្រោះក្រដល់ឆ្នាំក្រោយ ។
អ្នកក្រខ្ចីនេះកុំ អ្នកមានសុំនោះគួរអោយ
អ្នកប្រាជ្ញអង្គាសញ្ឆយ អស់ក៏ដោយអោយទៅចុះ ។
អ្នកក្របានជាហាម ពិបាកតាមទៅឯណោះ
ទាល់ទឹកចូលច្រមុះ ច្រើនកើតឈ្លោះពីព្រោះយល់ ។
អ្នកមានគេមានខ្មាស សងរហ័សមិនអំពល់
ជួនយើងមានរវល់ គេស្គាល់មុខស្រណុកខ្ចី ។
អ្នកក្រ១ទាំងចិត្ត ស្រូវផ្ការល្អិតអោយមើលល្អី
វាលល្អកន្លាំងបី ទាន់ស្រូវថ្មីទារឆាប់បាន ។
ជួនក្រែងឯងក្រវិញ ទោះដូរទិញមើលប្រមាណ
ជឿបុលខ្ចីសន្ធាន កុំហ៊ានពារកញ្ជើធំ ។
ខ្លួនក្រកុំចង់ធាត់ កុំងាយមាត់អាងតែសុំ
ជឿខ្ចីល្អីក្រមុំ ស្រូវឯងទុំស្រណុកសង ។
បើជឿខ្ចីគេអោយ កុំទៅញយគេអោយខ្មង
ឯណេះឯណោះផង កុំច្រើនដងគេមើលងាយ ។
ក្រលុយកុំងុយដេក ចូលដំណេកកុំនិយាយ
សំពត់ញាត់សំពាយ រាយរើសរៀបញាត់សំពៀត ។
រៀបដេកសំពះគុណ កុំដេកស៊ុនអោយប្រុងស្មៀត
ភ្លើងលេះយប់អធ្រាត្រ កណ្តៀតទូលប្រមូលរត់ ។

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ខ្លួនរាស្ត្រក្រមាសប្រាក់ ភើចកន្ទ្រាក់អាវសំពត់
ទំរាំភ្លើងរលត់ ស្លៀកផ្តង់ផ្តត់សោះខ្មាសគេ ។
កូនអើយគិតអោយគ្រប់ វៀងរាល់យប់កុំទំនេរ
ជាងដេកលក់ទទេ យល់សព្វដេរបកសាចក្រៅ ។
ទំលាប់មាត់មមើ ស្រែកថាយើៗ អៅៗ
ចោរខ្លាំងខ្មោចចិត្តខ្មៅ ហៅមេខ្មៃវៃអោយខ្នុក ។
ដេកផ្ទៀងជាងអង្គុយ ល្ងាល្ងាន់ល្ងុយកុំទ្រាំងក់
ពីល្ងាចដេកកុំលក់ មាន់រងាវជក់ស៊ីម្លូស្លា ។
ជាងល្ងីតឥតអំពើ ឥតអ្វីធ្វើសូត្រធម៌អាថិ
បើច្បាស់វិបស្សនា ស្មាស្មាធិ៍ស្ទឹងប្រឹងអោយស្មោះ ។
តំងខ្មើយដេកកើយស្មុគ្រ គ្រប់អោយសុខសូត្រអម្បោះ
កុំដាក់ដោយកៀនកោះ អស់នឹងសត្វកណ្តៀរកោរ ។
កណ្តុរកន្លាតកាត់ ដល់កំណាត់ខានដេរខោ
ជូនកាលមានអាចោរ លលបលួចលីទៅបាត់ ។
កុំដាក់ឆ្ងាយប្រយោល ទុកជាចោលមិនប្រយ័ត្ន
ប្រយោជន៍យប់យាមស្ងាត់ បង្កាត់ភ្លើងបង្គោលគោ ។
បង្ការក្រែងមូសខាំ ត្រូវចំណាំខ្យល់ជំនោរ
បាយកកផ្ដកម្ហូបជោរ អោយអាលោស៊ីចាំសេះ ។
កំណើតឆ្អែតញីឈ្មោល ដេកចំនួលតែនឹងផេះ
រៀនប្រើមើលចំណេះ វិះចំណាំតាមកិរិយា ។
ទោះប្រើកូនតូចធំ ឬប្រើខ្ញុំអោយធ្វើការ
ធ្វើកលយល់ប្រាជ្ញា អាណាហ៊ានប្រើទៅឆ្ងាយ ។
អាខ្លាចប្រើតែជិត ឥតគំនិតប្រើវៀងអាយ
ខុសម្តងកុំដេរម្តាយ ពេលដល់បាយកុំនាំឈ្លោះ ។
មនុស្សឃ្លានវាហ៊ានឆ្លើយ ស៊ីរួចហើយបន្ទោសចុះ
បានឆ្អែតប៉េងពេញពោះ ស្តីខុសត្រូវមិនសូវខឹង ។
កូនអើយពាក្យអាពុក ចំណាំទុកពីត្រឹមណឹង
ធ្វើប្រុសអោយខំប្រឹង រៀនអោយដឹងស្គាល់ពុតស្រី ។
មារយាទនិងមាយា ម៉្យាងចិត្តជាចេះថ្នមប្តី

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ប្ដូរស្លាប់រស់វាហើ យកពីរបីនេះមិនបាន ។
កុំលោភច្រើនៗ ព្រួយ យកតែមួយសុខក្សេមក្សាន្ត
ចិត្តស្រីទាំងប៉ុន្មាន ហ៊ានប្រមូលម៉ៅមិនខុស ។
មិនខូចគ្រប់តែស្រី ល្អពីរបីជឿចាំចុះ
ជាតិស្រីលោភលើប្រុស នោះមិនខុសពីស្រីណាមួយ ។
ខ្លាំងខ្សោយកុំអោយខ្សត់ ទោះនឿយហត់កុំលំអួយ
ធ្វើប្រុសតែងតែព្រួយ ស្រីមិនជួយកុំត្អូញត្អែរ ។
ខ្លួនខ្លាំងកុំគិតខ្លាច ស្រីៗ កាចស្លូតដោយខែ
រដូវធ្វើស្រូវស្រែ ចែប៉ប្រែស្ដីលើប្រុស ។
ខែស្ទូងនិងខែច្រូត កាចរហូតដល់ខែបុស្ស
ខែបែនបោករលស់ រលីងអស់អំពីដី ។
ជញ្ជូនដាក់ជង្រុក ពូជពេញទុកស្បៀងពីរបី
ដំណើបប្អូនដប់ល្អី ស្រីៗ ស្លូតហើយខែនឹង ។
ស្លូតផុតនៅខែមាឃ ស្ដីធ្ងន់ពាក្យមិនសូវធ្ងន់
បើប្រុសៗ មិនដឹង ប្រឹងតែព្រួតស្អប់ស្រីៗ ។
ម្យ៉ាងទៀតមារយាទខូច មាយាបេះក្រួចមាយាដកខ្ទី
មានប្រុសសាហាយថ្មី រឹតថ្នមប្ដីមិនអោយអាក់ ។
អីអើតែមាត់ក្រៅ ចិត្តមួម៉ៅគ្មានត្រជាក់
ត្រីសាច់ល្អលួចលាក់ ដាក់តែឆ្អឹងអោយឯងស៊ី ។
បញ្ឆោរចេះបញ្ចើ បញ្ឆោតប្រឹងវក់វី
វរវឹកព្រួតប្រុសពីរ ស៊ីទាល់ងាប់គាប់សងខាង ។
មួយទៀតផិតកំឡោះ ស្រឡាញ់ស្មោះស្ម័គ្រអស់យ៉ាង
លោមប្ដីលាសំណាង ទាស់ក្មេងក្មាងទារសំបុត្រ ។
បើប្ដីមិនព្រមលែង លបជំទែងជំទយរត់
មួយទៀតខូចបំផុត មត់អោយប្រុសសម្លាប់ប្ដី ។
ម្យ៉ាងទៀតមារយាទជា មានច្រើនគ្នាក្នុងលោកិយ
ប្រាកដពេញជាស្រី ប្រុសពីបីស្នាលាកម្ម ។
ស្លាប់រស់មួយនឹងមួយ មិនចង់ព្រួយយកប្រុសប្រាំ
ប្ដីស្លាប់ប្អូនដប់ឆ្នាំ ចាំសីលទានមិនមានទៀត ។.

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ធ្វើបុណ្យផ្សងសច្ចា សុំប្រាថ្នាជួបរាល់ជាតិ
អុចធូបដេកអោបធាតុ កណ្តៀតថោកោរកាន់ទុក្ខ ។
និយាយពីពុតប្រុស ចូរចាំចុះជាទំនុក
ដំណាតទៅមុខ អាពុកប្រាប់អោយស្រីចាំ ។
ប្រពន្ធមួយមិនស្កប់ ប្រពន្ធដប់គ្រាន់តែស្តាំ
កាចស្លូតរហូតឆ្នាំ ចាំដរាបដល់រូបា ។
កាចម៉្យាងខាងល្ងាចព្រឹក រឿងបាយទឹកថ្នាំម្លូស្លា
កាចម៉្យាងរឿងធ្វើការ ម៉្យាងទៀតណារឿងប្រចណ្ឌ ។
ប្រជុំជាតិចិត្តប្រុស ត្រូវនឹងខុសជាកំណាន់
គំនិតល្អសំខាន់ ប្រកាន់មើលឥរិយាបថ ។
ប្រចណ្ឌរាវរាល់ឈ្មោះ ច្រើនកើតឈ្លោះទៅជាខ្សត់
មួយឃើញជាក់ប្រាកដ ប្រកៀកចាប់ធ្វើទោសបាន ។
លកលែតែខាងប្រុស ប្រពន្ធខុសបង្អង់ខាន
ខូចម្តងខាតប៉ុន្មាន រាប់អានអោបក្រសោបទៀត ។
មួយលកលែទាំងពីរ នៅរកស៊ីដោយសារញាតិ
ស្រីមាយាឥតមារយាទ ស្មាលាជាតិមិនអោយជូន ។
ប្រចណ្ឌទាំងបីបទ គួគួចកត់ទុកក្នុងខ្លួន
លក់ពីពេញចំនួន គួនគំទុកយកជាច្បាប់ ។
ប្រចណ្ឌហើយយកទៀត ហៅជូជាតិមារយាទអាប់
កូនណាយកតម្រាប់ ស្លាប់នឹងស្រី១មើលងាយ ។
ទោសតិចកុំទាញផ្សំ ឃើញមិនចំកុំនិយាយ
កុំចាប់ស្តើររវើរវាយ នាំអោយវល់អំពល់ចិត្ត ។
ពុតប្រុសនិងពុតស្រី ចប់សេចក្តីពីក្បត់ជិត
រៀងរើសណាសុខចិត្ត គិតសំគាល់រាល់រូបកាយ ។
បើមានកូនក្រមុំ គួរតែកុំបណ្តោយឆ្ងាយ
អោយមើលនាយមើលអាយ ស្រេចនៅម្តាយរក្សាកូន ។
ប្រយ័ត្នកុំអោយឃ្លាត ភ្លាត់មារយាទមិនសុទ្ធសូន្យ
កុំទុកចិត្តបងប្អូន ជីដូនមួយជួយរក្សា ។
ក្រមុំមានម្រាក់មិត្ត មេមួយគិតនាំកិច្ចការ

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKorHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



កុំជឿចិត្តនរណា មើលកិរិយានៃកូនឯង ។
ទោះស្ទូងដកយប់ថ្ងៃ ដើរយកដៃដាច់សង្វែង
ប្រុសខូចលួចបន្លែង តែទាស់ភ្នែកបែកមេបា ។
ច្រើនណាស់តែសែនខ្មោច កើ្តអសោចផុតអាសា
នាំកូនឡើងសាលា គេថាអោយជំងឺចិត្ត ។
បើមានកូនប្រសា មិនទាន់ការគួរអោយប្រិត
កុំអោយបំរើឆ្អិត អាណិតវា១សងគុណ ។
យប់ថ្ងៃចូលប្រតិបត្តិ គាតក្រវាត់រត់រែកពុន
អាចនឹងច្រើនជឿមុន ស៊ុនអំពីឪពុកម្តាយ ។
រក្សាកូនប្រពូន រកទ្រព្យធនចង់ធូរចាយ
ជួញជិតគំនិតឆ្ងាយ ជួញវៀងអាយរក្សាគុណ ។
អំពើបាបកុំរៀន កុំអៀនប្រៀនក្នុងការបុណ្យ
លាងទោសចេញជាមុន ទើបធ្វើបុណ្យចំរើនផល ។
បើនឹងចង់គង់ទ្រព្យ កុំទម្លាប់សាងអកុសល
របិញរបុញវៀចកាច់កល់ ទេវតាផ្តល់ផ្តាច់ធនធាន ។
កុំឈ្នានីសអ្នកក្សត្រ កុំបំភ្លាត់ទ្រព្យអ្នកមាន
បើខ្លួនខ្សត់អត់ឃ្លាន រៀនតែរកតាមទ្បៀងត្រង់ ។
ជួញខាតកុំឈប់ខាន បើចង់បានកុំឃ្លាចបង់
ខ្លាចបាត់អោយផ្ទិតផ្ទង់ ប្រុងថៃទាំអោយមាំមួន ។
កុំភ្លើធ្វើជាភ្លេច ភ្លាត់បន្តិចខ្លាចក្រែងជូន
ក្រែងចោរចូលមកពួន លួនលបលួចយកទ្រព្យទៅ ។
ប្រហែសតែងតែបាត់ ប្រុងប្រយ័ត្នតែងតែនៅ
គិតសព្វគ្រប់ដោយផ្លូវ សូវទ្រាំនឿយកុំទ្រាំក្រ ។
នៅផ្ទះស្រះរបង របាចងអោយជាប់ល្អ
ប្រើប្រាស់ខ្ញុំកំដរ អោយបរិភោគដោយខ្លួនឯង ។
នឹងប្រើទៅហៅមក កុំគំហកយកកំហែង
កុំហាឡើងហងឯង ក្រែងកំហល់ទល់កំហឹង ។
កុំហួសពាក្យសម្តី ការអ្វី១អោយចេះថ្លឹង
កុំប្រើព្រួតលើប្រើង ក្រែងកើតខឹងវានាំខាត ។

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



មនុស្សខឹងច្រើនៗខុស មនុស្សច្រើនឈ្លោះច្រើនប្រមាថ
ការល្អមិនត្រូវខ្ចាត យើងចង់ស្អាតមិនខ្លាចយូរ ។
ចង់ប្រាជ្ញអោយខំប្រឹង ចងក្បិនតឹងរកស៊ីធូរ
តំនិតមុនតំនូរ រៀនមានគ្រូមានគេរាប់ ។
បំរើឪពុកម្តាយ អ្នកនៅឆ្ងាយគេច្រើនគាប់
អ្នកណាបំរើខ្ជាប់ ធ្លាប់តែខុសមិនដែលត្រូវ ។
ជាតិមនុស្សទោះខ្ពស់ទាប មិនចោលភាពពីម៉ែឪ
ពាក្យមនុស្សវែងជាងផ្លូវ ស្រូវច្រើនខ្ចបខ្ចូចអង្ករ ។
របស់ទ្រព្យថោកថ្លៃ ទុកសំចៃលៃអោយល្អ
អុងអាងពាងក្រឡ ត្រដរទិញកុំអោយខ្វះ ។
កើតមកខ្លួនជារាស្ត្រ ក្រប្រាក់មាសអោយមានខ្នាស
សារពើគ្រឿងប្រើប្រាស់ អោយមានចាស់អោយមានថ្មី ។
ពូថៅដឹងកាំបិត ពន្លាកខិតចបវែងខ្លី
ខ្សែសេះគោក្របី ឫស្សីផ្តៅកាច់សង្រែក ។
ការងារកុំអោយក្រ អាកក្រក់ល្អមានដោយឡែក
ថ្ងៃនេះរបេះបាក់បែក ស្អែកខំរើធ្វើជាឆាប់ ។
ឈ្មោះការប្រើលើដី កុំចាំស្រីតឿនប្រើប្រាប់
អោយមានគ្រប់ប្រដាប់ សំរាប់រាល់អោយសល់ប្រើ ។
កុំខ្ជិលល្ងង់ខ្លៅពេក អោយចេះដេកអោយចេះដើរ
ចេះសព្វគាប់ប្រសើរ កុំចង់ហើរហួសភាពខ្លួន ។
ចង់ក្តីអោយរៀនច្បាប់ រស់នឹងស្លាប់អោយចេះក្បួន
ចេះអ្វីចេះអោយមួន កុំបន្ទំផ្ទំនឹងគេ ។
កុំដេកចាំសំណាង កុំក្អេងក្អាងចាំបុព្វេ
ខំរកកុំទំនេរ រវៀនរិះចេះអោយគ្រប់ ។
នឹងដើរស្វែងរកផល មិនទាន់ដល់កុំអាលឈប់
ឈានខ្លាំងពេកជំពប់ បើដេកយប់អោយស្គាល់យាម ។
កុំដេកយូរទ្រមឹក លកហួសព្រឹកខុសទំនៀម
តែភ្លឺឡើងភ្ញាក់ភ្លាម ព្រហាមឡើងក្រោកធ្វើការ ។
ជាតិមនុស្សទោះប្រុសស្រី រាស្ត្រមន្ត្រីជាធម្មតា

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ពេលព្រឹកតែងឧស្សាហ៍
ចង់ធំខំពីតូច
ការអ្វីអោយចេះថ្លឹង
កុំចង់ខ្ពស់ស្មើមេឃ
ទោះដើរនិយាយស្តី
យល់ឆ្ងាយកុំណាយគិត
មិនជាក់មើលអោយចំ
ទម្លាប់ធំជាងច្បាប់
គ្រាប់ប្រាជ្ញអាចប្រដៅ
ស្រឡាញ់កុំញ៉េះញ៉ោះ
ផ្អែព្រុះកុំអោយព្រួយ
កំណប់ដប់សំពាយ
សំឡឹងមើលអោយសព្វ
ក្តីឈ្នះគេចុះចាញ់
បើខឹងកុំរំលោភ
កុំរមាត់ក្រែងភ្លាត់ស្មៀត
កំណើតអាក្រក់ល្អ
ពីកាលបុព្វេពិត
ដាំដូងអោយខំថែ
បើជូនសំណាងដល់
ប្រាជ្ញប្រិតប្រៀនប្រដៅ
រំពឹងក្នុងប្រាជ្ញា
នេះច្បាប់កេរកាលថ្មី
កូនប្រុសអ្នកខំប្រឹង
ពីឆ្នាំ ច តទៅ
អាសូរពាក្យអាពុក
អាពុកកាន់តែចាស់
ពាក្យពិតប្រាំរយឃ្លា
អ្នកប្រាជ្ញភិរម្យល្បី

ថ្ងៃក្តៅល្ហខ្ជិលល្អិតឆ្អឹង ។
បើខ្លាចខូចកុំឆាប់ខឹង
កុំប្រឹងជុះតាមដើរ ។
កុំខិនពេកអាប់រាសី
លែអោយល្មមតែគួរសម ។
ទោះយល់ជិតកុំអាលខំ
ក្រែងច្រឡំសជាខ្មៅ ។
បើរៀនគ្រាប់កុំគ្រាប់ខ្លៅ
អោយគេរៀនកំអោយអស់
បើខឹងទាស់កុំអោយទាយ ។
ឃើញផ្អែដេកកុំមើលងាយ
កុំនិយាយប្រាប់សំឡាញ់ ។
បើនឹងស្អប់កុំអាលបាញ់
កុំភ្ចាច់តាមផ្គន្ទាទៀត ។
បើនឹងល្មោភអោយល្មមមាឌ
វាតហួសវង់ផុតគំនិត ។
មាននឹងក្រពីគំនិត
ងងឹតពេកមើលមិនយល់ ។
ចង់ស៊ីផ្លែអោយដុតគល់
រវល់តែស៊ីឆ្ងាញ់ពិសា ។
ចូរកូនចៅពិចារណា
ស្រាយបញ្ហានេះអោយដឹង ។
អស់សេចក្តីតែប៉ុណ្ណឹង
សំឡឹងចាំតទៅមុខ ។
ខំធ្វើស្រូវដាក់ជង្រុក
ទុកអោយកូនចៅគ្រប់គ្នា ។
ស្តាយខ្លួនណាស់ចូលជរា
ជាសូរចម្លែះឯងហោង ។
លើកច្បាប់ថ្មីអស់ល្បត់ល្បង

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ឈ្មោះ ឡឹ ហៅ ខ៊ុយ ផង
ខ្ញុំសូមផ្សងសច្ចា
មូលកូនមូលប្រពន្ធ
ស្ថាលោក្រលំបាក
សូមល្អពង្សរូបកាយ
ប្រាជ្ញាកុំទើសទាល់
សូមជាប់សីលបរិសុទ្ធ
អានិសង្សបុណ្យខ្ញុំបាន
សម្បត្តិសួគ៌ាល័យ
ពីជាតិនេះទៅមុខ
បងប្អូនកុំខ្វាត់ខ្វាយ

ចងជាច្បាប់សំរាប់ជន
កើតជាតិណាសូមមានបុណ្យ
ធនសម្បត្តិសម្បូរចាយ
សូមជៀសចាកចតុរាបាយ
កុំអោយឆ្ងាយពីព្រះពុទ្ធ
ចេះអាថ៌ធមិអោយមាំមុត
រលត់ទុកសោករោគភ័យ
សាងបុ៉ន្មានក្នុងលោកិយ
កុំបីឃ្លាតរវាតវែងឆ្ងាយ ។
មូលអាពុកជួបមូលម្តាយ
អធិប្បាយថែងចប់ឯវិ

អ្នកព្រះភិរម្យភាសា ឡឹ ហៅ ខ៊ុយ

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel